SWIS-H
STATEWIDE INFANT SCREENING - HEARING



# ហេតុអ្វីបានជាទារករបស់ខ្ញុំត្រូវការ ការពិនិត្យមើលសោតវិញ្ញាណ?

ទារករបស់អ្នកនឹងបានទទួលការឆែកពិនិត្យមើលសុខភាពជាបន្តបន្ទាប់ ក្នុងអំឡុងពេល ២-៣សប្តាហ៍ដំបូងបន្ទាប់ពីបានកើតមក។ ការឆែកពិនិត្យមើលមួយក្នុងចំណោមការឆែកពិនិត្យទាំងនេះ គឺដើម្បីរកមើលការបាត់បង់សោតវិញ្ញាណ(ការស្តាប់មិនសូវឮ)។ ការពិនិត្យមើលសោតវិញ្ញាណនឹងបានផ្តល់យ៉ាងឆាប់តាមលទ្ធភាពអាចធ្វើទៅបាន បន្ទាប់ពីបានកើតមក។

ប្រសិនបើគេពុំអាចផ្តល់ជូនការពិនិត្យមើលសោតវិញ្ញាណបានទេក្នុងពេលដែលអ្នក និងទារករបស់អ្នកកំពុងនៅក្នុងមន្ទីរពេទ្យ ទារករបស់អ្នកនឹងបានទទួលការពិនិត្យមើលសោតវិញ្ញាណក្នុងភាពជាអ្នកជំងឺពុំដេកក្នុងមន្ទីរពេទ្យ ឬនៅតាមទីកន្លែងសហគមន៍ក្នុងតំបន់ក្នុងពេលឆាប់ៗ ក្រោយពេលចាកចេញពីមន្ទីរពេទ្យ។

## ហេតុអ្វីបានជាទារករបស់ខ្ញុំត្រូវការ ការពិនិត្យមើលសោតវិញ្ញាណ?

មានទារកប្រហែល១នាក់ ទៅ២នាក់ ក្នុងចំណោមទារក១០០០នាក់ ដែលកើតមក នឹងមានការបាត់បង់សោតវិញ្ញាណដ៏ធ្ងន់ធ្ងរ។

ជាការសំខាន់ដែលអ្នកត្រូវស្វែងយល់ឲ្យបានដឹងយ៉ាងឆាប់ តាមលទ្ធភាពអាចធ្វើទៅបានថាតើទារករបស់អ្នកស្តាប់ឮល្អយ៉ាងណាដែរដើម្បីឲ្យអ្នក ហើយនិងទារករបស់អ្នកអាចទទួលបានឱវាទ និងការផ្តត់ផ្គង់ត្រឹមត្រូវ។ មកទល់នឹងពេលដែលក្មេងចាប់ផ្តើមចេះនិយាយពាក្យមួយម៉ាត់ដំបូងរបស់គេនោះ គេបានស្តាប់នូវភាសាដែលយើងនិយាយអស់រយៈពេលប្រហែលជាមួយឆ្នាំមកហើយ។

## តើការពិនិត្យមើលទារករបស់ខ្ញុំទាក់ទិននឹងអ្វីខ្លះ?

អ្នកពិនិត្យមើលសោតវិញ្ញាណដែលមានការហ្វឹកហ្វឺន នឹងចាត់ចែងការពិនិត្យមើលនៅពេលទារករបស់អ្នកកំពុងគេង ឬសម្រាកយ៉ាងស្ងៀមស្ងាត់។ អ្នកត្រូវបានស្វាគមន៍ឲ្យនៅជាមួយទារករបស់អ្នកក្នុងអំឡុងពេលដែលគេកំពុងពិនិត្យមើល។

អ្នកពិនិត្យមើលនឹងដាក់បន្ទះគ្រឿងប្រដាប់ទទួលសញ្ញាតូចមួយនៅលើក្បាលរបស់ទារកអ្នក ហើយធ្វើសម្លេងគោះស្រាលៗក្នុងត្រចៀករបស់ទារក តាមរយៈឧបករណ៍សម្រាប់ពាក់ស្តាប់សម្លេង។ បន្ទះគ្រឿងប្រដាប់ទទួលសញ្ញានេះកត់ត្រាការឆ្លើយតបរបស់ទារកអ្នកទៅនឹងសម្លេង។

ការពិនិត្យមើលសោតវិញ្ញាណ តាមធម្មតាពុំរំខានឆាឆៅទារកឡើយ។ ការពិនិត្យមើលអាចប្រើពេល១០-២០នាទីដើម្បីបំពេញរួចរាល់។

NSW GOVERNMENT | Health

## លទ្ធផល

ក្រោយការពិនិត្យមើលសោតវិញ្ញាណបានបំពេញរួចភ្លាមនោះ គេនឹងពន្យល់ប្រាប់លទ្ធផលជូនអ្នក ហើយកត់ត្រាក្នុងកំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ទារកអ្នក (សៀវភៅខៀវ)។

ប្រសិនបើលទ្ធផលបង្ហាញថាមានតម្រូវការពិនិត្យមើលម្តងទៀត ការនេះមិនចាំបាច់មានន័យថាទារករបស់អ្នកបានបាត់បង់សោតវិញ្ញាណឡើយ។ វាអាចមានហេតុផលឯទៀតចំពោះការទទួលបានលទ្ធផលនេះ។ ហេតុផលទូទៅភាគច្រើនដែលតម្រូវឲ្យមានការពិនិត្យមើលម្តងទៀតគឺការមានវត្ថុរាវ ឬការរាំងខ្ទប់ក្នុងត្រចៀករបស់ទារកអ្នកក្រោយពេលកើតមក។

## តើខ្ញុំត្រូវការធ្វើអ្វីខ្លះក្នុងកាលទារករបស់ខ្ញុំមានវ័យកាន់តែធំឡើង?

សោតវិញ្ញាណអាចមិននៅដដែលដូចគ្នាតាមកាលកន្លង។

ជាការសំខាន់ដែលត្រូវពិនិត្យមើលការលូតលាស់ផ្នែកនិយាយស្តី និងភាសារបស់ទារកអ្នក ដូចគ្នានឹងការឆ្លើយតបរបស់គេទៅនឹងសូរសម្លេងដែរ។

អ្នកអាចយោងទៅបញ្ជីឆែកមើលនៅទំព័រម្ខាងទៀត ដើម្បីពិនិត្យមើលការលូតលាស់របស់កូនអ្នក។

ប្រសិនបើអ្នកមានកង្វល់អំពីសោតវិញ្ញាណ ឬការលូតលាស់ផ្នែកនិយាយស្តី និងភាសារបស់ទារកអ្នកនៅពេលអនាគត សូមរៀបចំឲ្យមានការធ្វើតេស្តសោតវិញ្ញាណសម្រាប់ទារកអ្នក។ ស្នើសុំវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់អ្នកឲ្យគេបញ្ជូនអ្នកទៅកាន់សេវាកម្មសមស្របណាមួយ ដើម្បីទទួលការធ្វើតេស្តសោតវិញ្ញាណរបស់ទារកអ្នក។

ការធ្វើតេស្តសោតវិញ្ញាណអាចធ្វើបាននៅគ្រប់អាយុ។

### សម្រាប់ព័ត៌មានបន្ថែម សូមបើកចូលវ៉ិបសាយខាងក្រោមនេះ៖

http://www.health.nsw.gov.au/kids-families

ការទាក់ទងក្នុងតំបន់ / ព័ត៌មានលំអិតអំពីការណាត់ជួប

សម្រាប់ឱវាទផ្នែកសុខភាព សូមទាក់ទង *healthdirect Australia*
http://www.healthdirect.gov.au/
**1800 022 222**

SWIS-H
STATEWIDE INFANT SCREENING - HEARING

# បញ្ជីផែនកមើលសោតវិញ្ញាណ

| | |
|---|---|
| ចាប់ពីកំណើត ទៅ៣ខែ | បញ្ចេញប្រតិកម្មទៅនឹងសូរសម្លេងខ្លាំង |
| | ទៅជាស្ងប់ស្ងៀមជាមួយនឹងសម្លេង ឬសូរកងរំពងដែលធ្លាប់ឮ |
| | ធ្វើសម្លេងថ្ងូរ |
| | ឆ្លើយតបទៅនឹងការនិយាយស្ដី ដោយសម្លឹងមើលមុខអ្នកនិយាយ |
| ៣-៦ខែ | បែរភ្នែក ឬក្បាលឆ្ពោះទៅរកសម្លេង |
| | ចាប់ផ្ដើមបញ្ចេញសម្លេងដូចការនិយាយស្ដី |
| | សើច ហើយធ្វើសម្លេងដើម្បីបង្ហាញប្រាប់អំពីអារម្មណ៍របស់គេ |
| ៦-៩ខែ | និយាយកកែកករ ´ដាដា´ ´ម៉ា-ម៉ា´ ´បាបា´ |
| | ស្រែក /បន្លឺសម្លេងដើម្បីទាក់ទាញអារម្មណ៍ |
| | ជាញឹកញយ នឹងឆ្លើយតបទៅពាក្យ´ កុំ ឬ ទេ´  ហើយស្គាល់ឈ្មោះរបស់ខ្លួន |
| | ឆ្លើយតបទៅនឹងចម្រៀង និងភ្លេង |
| ៩-១២ខែ | ត្រាប់តាមសម្លេងនិយាយស្ដីរបស់មនុស្សឯទៀត |
| | យល់ពាក្យសាមញ្ញទាំងឡាយដូចជា ´បាល់´ ´ឆ្កែ´ ´ប៉ា´ |
| | ងាកក្បាលទៅរកសម្លេងស្រាលៗ |
| | និយាយពាក្យដំបូងមួយចំនួន |
| ១២-១៨ខែ | ហាក់បីដូចជាយល់ពាក្យថ្មីៗរៀងរាល់សប្ដាហ៍ |
| | ធ្វើតាមពាក្យនិយាយណែនាំសាមញ្ញមួយចំនួនដូចជា ´ទៅយកបាល់ ´ |
| | ចង្អុលទៅមនុស្ស ផ្នែកនៃដងខ្លួន ឬប្រដាប់ក្មេងលេងពេលណាគេសួរ |
| | បន្តរៀននិយាយពាក្យថ្មីៗ ថ្វីដ្បិតតែពាក្យទាំងនោះប្រហែលជាមិនសូវច្បាស់ក្ដី |
| ១៨-២៤ខែ | មានប្រមាណជា១០០ -  ២០០ពាក្យដែលគេប្រើជាញឹកញាប់ |
| | ស្ដាប់រឿងនិទាន ឬចម្រៀងសាមញ្ញ |
| | បញ្ចូលពាក្យពីរ ឬបីជាឃ្លាខ្លីៗ ឧទាហរណ៍ ´ទឹកច្រើន´ |

កំណត់ចំណាំ:

NSW GOVERNMENT | Health

© NSW Health September 2016
SHPN (NKF)150163